LOS ANGELES COUNTY
DEPARTMENT OF MENTAL HEALTH
hope. recovery. wellbeing.

# តុលាការថែទាំ (CARE Court) - ធនធានសុខភាពផ្លូវចិត្តថ្មី: ការជំរុញការស្តារឡើងវិញ និងការពង្រឹងអំណាច

ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី: 11.16.2023

## តើអ្វីជា CARE Court

មនុស្សនៅក្នុងសហគមន៍របស់យើង ជួបប្រទះជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ហើយប្រហែលជាមិនបានទទួលជំនួយទៀងទាត់ ដែលជារឿយៗបណ្តាលឱ្យគ្មានផ្ទះសម្បែង និងការប្រើប្រាស់សារធាតុញៀន។ មនុស្សជាទីស្រឡាញ់របស់ពួកគេ និងអ្នកមើលថែផ្សេងទៀត តែងតែជួបការលំបាកក្នុងការស្វែងរកជំនួយ និងជំនួយសង្គ្រោះជីវិត។

ឡូសអេនជីឡេសខោនធី កំពុងចាប់ផ្តើមកម្មវិធីថ្មីមួយ ដែលផ្តល់មូលនិធិដោយរដ្ឋហៅថា, ជំនួយសហគមន៍, ការស្តារឡើងវិញ និងការផ្តល់សិទ្ធិអំណាច (CARE) Court, ដែលជួយមនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ និងដែលមិនបានទទួលការព្យាបាល ដូចជាជំងឺវិកលចរិក, ទទួលការព្យាបាល និងសេវាកម្មសម្រាប់សុខភាព និងសុខុមាលភាពរបស់ពួកគេ។ អ្នកចូលរួម អាចទទួលបានការគាំទ្រជាច្រើនប្រភេទ ដែលអាចរួមបញ្ចូលការប្រឹក្សា ឱសថ លំនៅដ្ឋាន សេវាសង្គម និងផ្សេងៗទៀត។ ជាជាងការរិលវល់ជាមួយនឹងពន្ធនាគារ និងបន្ទប់សង្គ្រោះបន្ទាន់, តុលាការ CARE ផ្តល់ឱ្យបុគ្គលដែលងាយរងគ្រោះ និងអ្នកដែលថែទាំពួកគេ នូវមាគ៌ាមួយផ្សេងទៀត ដើម្បីទទួលបាននូវសេវាកម្មសំខាន់ៗដែលអាចជួយរក្សាសុវត្ថិភាពពួកគេ។ សមាជិកគ្រួសារ មិត្តរួមបន្ទប់ គ្រូពេទ្យព្យាបាល និងអ្នកផ្សេងទៀតអាចដាក់បណ្តឹងទៅតុលាការ ដើម្បីស្វែងរកការអនុម័តនូវកម្មវិធីនេះ។

The Los Angeles County Department of Mental Health (LACDMH) មានសេចក្តីសោមនស្សរីករាយក្នុងការផ្តល់ជូនតុលាការ CARE ជាផ្នែកនៃកម្មវិធីបន្ថែម ដើម្បីផ្តល់ជំនួយសុខភាពផ្លូវចិត្ត សម្រាប់អ្នកដែលត្រូវការវា។

## តើកម្មវិធី **CARE** ផ្តល់សេវាកម្មអ្វីខ្លះ?

ក្រុមអ្នកជំនាញ រួមទាំងវេជ្ជបណ្ឌិត ទីប្រឹក្សា អ្នកគ្រប់គ្រង ករណី អ្នកដែលមានបទពិសោធន៍ផ្ទាល់ និងអ្នកផ្សេងទៀត ធ្វើការជាមួយអ្នកចូលរួមម្នាក់ៗ ដើម្បីបង្កើតផែនការ CARE ដែលជាផែនការព្យាបាលលក្ខណៈផ្ទាល់ខ្លួន ដែលស្របតាមតម្រូវការជាក់លាក់របស់ពួកគេ។ ផែនការ CARE អាចរួមបញ្ចូលជំនួយជាច្រើនប្រភេទ ដែលអាចរួមបញ្ចូលការប្រឹក្សា ឱសថ លំនៅដ្ឋាន សេវាសង្គម និងផ្សេងៗទៀត។ ផែនការថែទាំនេះ មិនមែនអនុលោមទាំងស្រុងតាមផែនការដែលបានបង្កើតនោះទេ ហើយអ្នកដែលចូលរួមនៅតែមានសមត្ថភាពក្នុងការបង្ហាញពីចំណូលចិត្តរបស់ពួកគេ អំពីការព្យាបាល និងធ្វើការសម្រេចចិត្តដោយខ្លួនឯង អំពីការចូលរួមក្នុងកម្មវិធី ថាតើត្រូវលេបថ្នាំឬអត់ និងទិដ្ឋភាពផ្សេងទៀត នៃការថែទាំរបស់ពួកគេ។

## តើអ្នកណា មានសិទ្ធិចូលរួម?

កម្មវិធី CARE មានគោលបំណងជួយមនុស្សពេញវ័យ ដែលជួបប្រទះនូវ **ប្រភេទជាក់លាក់** នៃជំងឺផ្លូវចិត្តធ្ងន់ធ្ងរ និងដែលមិនទាន់បានព្យាបាល។ ដើម្បីមានសិទ្ធិចូលរួមកម្មវិធី CARE អ្នកចូលរួម **ត្រូវតែ៖**

- 18 ឆ្នាំ ឬចាស់ជាងនេះ។
- ត្រូវបានគេធ្វើរោគវិនិច្ឆ័យ ថាមានជំងឺវិកលចរិក ឬជំងឺផ្លូវចិត្តផ្សេងទៀត។
- បច្ចុប្បន្នកំពុងជួបប្រទះអាកប្បកិរិយា និងរោគសញ្ញានានា ដែលទាក់ទងនឹងជំងឺផ្លូវចិត្តធ្ងន់ធ្ងរ។
- មិនបានទទួលការព្យាបាលដោយមានស្ម័គ្រចិត្ត ជាបន្តបន្ទាប់កន្លងមកនេះ

ដើម្បីស្វែងយល់បន្ថែម ថាតើមនុស្សជាទីស្រលាញ់របស់អ្នកមានសិទ្ធិសម្រាប់កម្មវិធី CARE និងមានសំណួរបន្ថែម សូមចូលមើលគេហទំព័រ **dmh.lacounty.gov/care-court** ឬទូរស័ព្ទទៅលេខ 1-800-854-7771.

សូមឆ្លៀតពេលដើម្បីស្វែងយល់ អំពីសិទ្ធិដែលអាចទទួលបាន មុននឹងឈានទៅកាន់ដំណើរការដាក់បណ្តឹងញត្តិជាផ្លូវការ។

មិនមែនគ្រប់គ្នា សុទ្ធតែមានសិទ្ធិគ្រប់គ្រាន់ក្នុងទទួលបានសេវា CARE នោះឡើយ។ ទោះជាយ៉ាងនេះក្តី LACDMH ផ្តល់កម្មវិធីបន្ថែមជាច្រើន ដែលអាចជួយបាន។

Chief Executive Office.

CARE Court
LA County Caring Together

## តើខ្ញុំអាចចាប់ផ្តើមដំណើរការ **CARE** ដោយរបៀបណា?

ដំណើរការចាប់ផ្តើម នៅពេលដែលសមាជិកគ្រួសារ មិត្តរួមបន្ទប់ គ្រូពេទ្យព្យាបាល ឬអ្នកដែលមានសិទ្ធិផ្សេងទៀត ដាក់បណ្តឹង CARE Act។ ចៅក្រមកំណត់ថា តើអ្នកចូលរួមដែលមានសក្តានុពល ត្រូវនឹងលក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធី CARE ដែរឬទេ។

ប្រសិនបើអ្នកចូលរួម ត្រូវបានទទួលយកទៅក្នុងកម្មវិធី CARE, ក្រុមការងារ CARE របស់ពួកគេ ធ្វើការជាមួយពួកគេ ដើម្បីបង្កើតផែនការ ដែលនឹងផ្តល់សេវាកម្មស្របតាមតម្រូវការរបស់ពួកគេ។ ផែនការនេះ នឹងផ្តល់សេវាកម្មបុគ្គលរហូតដល់មួយឆ្នាំ ដែលអាចនឹងបន្តរយៈពេលមួយឆ្នាំបន្ថែមទៀត ប្រសិនបើត្រូវបានជ្រើសរើស ឬមានតម្រូវការ។ សវនាការពិនិត្យឡើងវិញ នឹងត្រូវបានកំណត់ពេលធ្វើយ៉ាងទៀងទាត់ ដើម្បីវាយតម្លៃលើការវិឌ្ឍន៍ និងធានាថា សេវាកម្មត្រូវបានផ្តល់ជូនយ៉ាងឆាប់រហ័ស។

## តើអ្នកចូលរួម មានសិទ្ធិអ្វីខ្លះ?

កម្មវិធី គឺដោយការស្ម័គ្រចិត្តយ៉ាងតឹងរ៉ឹងបំផុត។ គោលដៅរបស់កម្មវិធី CARE គឺដើម្បីជួយប្រជាពលរដ្ឋ ក្នុងការទទួលបានការគាំទ្រដែលពួកគេត្រូវការ ក្នុងកម្រិតនៃការរឹតបន្តឹងអោយបានតិចបំផុត ដែលអាចធ្វើទៅបាន។ វាការពារសិទ្ធិរបស់អ្នកចូលរួមក្នុងការធ្វើការសម្រេចចិត្តដោយខ្លួនឯង ដោយផ្តល់ឱ្យពួកគេនូវតំណាងស្របច្បាប់ដោយឥតគិតថ្លៃ និងអនុញ្ញាតឱ្យពួកគេជ្រើសរើសអ្នកគាំទ្រ ដែលអាចជួយពួកគេស្វែងរកផ្លូវនៅទូទាំងដំណើរការនេះ។ អ្នកចូលរួមមិនអាចបង្ខំឱ្យចូលរួមក្នុងសេវាកម្ម ប្រឆាំងទៅនឹងឆន្ទៈរបស់ពួកគេឡើយ (រួមទាំងការលេបថ្នាំ) ហើយអាចចាកចេញពីកម្មវិធីនៅពេលណាក៏បាន។ មិនមានការពិន័យរដ្ឋប្បវេណី ឬព្រហ្មទណ្ឌសម្រាប់ការជ្រើសរើសមិនចូលរួមក្នុងដំណើរការនៃកម្មវិធី CARE នោះទេ។

## ចុះបើនរណាម្នាក់មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ កម្មវិធី **CARE?**

ប្រសិនបើនរណាម្នាក់ដែលអ្នកស្គាល់ ត្រូវការជំនួយ មានធនធានជាច្រើននៅទីនោះ ដើម្បីរក្សាសុវត្ថិភាព និងជួយដល់សុខុមាលភាពរបស់ពួកគេ។

### ទូរស័ព្ទ ឬផ្ញើសារជាអក្សរ ទៅលេខ **988**

ដើម្បីទាក់ទងជាមួយខ្សែរទូរស័ព្ទសង្គ្រោះការធ្វើអត្តឃាត និងវិបត្តិក្នុងជីវិត សម្រាប់ជំនួយបញ្ហាផ្លូវចិត្តដែលទាក់ទងនឹងសុខភាព។

### ទូរស័ព្ទទៅលេខ **1-800-854-7771** (ខ្សែទូស័ព្ទជំនួយ **24/7**)

សម្រាប់ក្រុមឆ្លើយតបវិបត្តិនៅតាមមូលដ្ឋាន ឬធនធានសុខភាពផ្លូវចិត្តតាមរយៈ LACDMH។

### ផ្ញើសារជាអក្សរ **"LA"** ទៅកាន់លេខ **741741**

ដើម្បីភ្ជាប់ជាមួយអ្នកប្រឹក្សាដោះស្រាយវិបត្តិ ដែលបានទទួលការបណ្តុះបណ្តាល ដើម្បីទទួលបានជំនួយក្នុងការដោះស្រាយវិបត្តិដោយឥតគិតថ្លៃ តាមរយៈសារជាអក្សរ។

ដើម្បីស្វែងយល់បន្ថែម អំពីកម្មវិធី CARE និងធនធានផ្សេងទៀត ដើម្បីជួយអ្នកដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ចូលមើលគេហទំព័រ
**dmh.lacounty.gov/get-help-now**

ដើម្បីស្វែងយល់បន្ថែម អំពីកម្មវិធី **CARE** និងធនធានផ្សេងទៀត ដើម្បីជួយអ្នកដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ចូលមើលគេហទំព័រ **dmh.lacounty.gov/care-court**